**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ. ធ៥ ០១៩ ៣៤៩ ធ.ស.ក

ថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង
## ការដេញថ្លៃប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី៣៤

ធនាគារជាតិនៃកម្ពុជា សូមជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ជ្រាបថា ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) លើកទី៣៤ ត្រូវដាក់ឱ្យដេញថ្លៃនៅថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ និងមានថ្ងៃប្រសិទ្ធភាពនៅថ្ងៃព្រហស្បតិ៍ ៥រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩។ ព័ត៌មានពាក់ព័ន្ធនឹងការដេញថ្លៃនេះមានដូចតទៅ៖

- ពេលវេលាដាក់ដេញថ្លៃ : ចាប់ពីម៉ោង ៨:០០ ព្រឹក ដល់ ១២:០០ ថ្ងៃត្រង់
- នីតិវិធីដេញថ្លៃ : ទឹកប្រាក់ដាក់ដេញថ្លៃជាលានរៀល (លេខមូល) និងអត្រាការប្រាក់ដាក់ដេញថ្លៃជាភាគរយ (ពីរខ្ទង់ក្រោយក្បៀស)។
- វត្ថុធានា : NCD ជាវត្ថុធានាត្រូវមានតណាប្រតិទានធំជាង ឬស្មើនឹងតណាប្រតិទានរបស់ LPCO
- ទំហំទឹកប្រាក់ដេញថ្លៃអប្បបរមា : ២០០.០០០.០០០ (ពីររយលាន) រៀល
- ទំហំទឹកប្រាក់ដេញថ្លៃអតិបរមា : LPCO ប្រភេទ ៩១ថ្ងៃ ចំនួន ២៥.០០០.០០០.០០០ (ម្ភៃប្រាំប៊ីលាន)រៀល
  LPCO ប្រភេទ ១៨២ថ្ងៃ ចំនួន ២៥.០០០.០០០.០០០ (ម្ភៃប្រាំប៊ីលាន)រៀល
  LPCO ប្រភេទ ៣៦៤ថ្ងៃ ចំនួន ៥០.០០០.០០០.០០០ (ហាសិបប៊ីលាន)រៀល

ទំហំទឹកប្រាក់ដាក់ឱ្យដេញថ្លៃ អត្រាការប្រាក់ Haircut លើវត្ថុធានា និងថ្ងៃតណាប្រតិទាន មានដូចតទៅ៖

| ប្រភេទ LPCO | តណាប្រតិទាន | ទឹកប្រាក់ដាក់ឱ្យដេញថ្លៃ | អត្រាការប្រាក់ដាក់ដេញថ្លៃអប្បបរមា | Haircut លើ USD-NCD |
|---|---|---|---|---|
| ៩១ថ្ងៃ (D091) | ២២ សីហា ២០១៩ | ១០០ (មួយរយប៊ីលាន) រៀល | ២,៦០% | ៣% |
| ១៨២ថ្ងៃ (D182) | ២១ វិច្ឆិកា ២០១៩ | ១០០ (មួយរយប៊ីលាន) រៀល | ២,៨៥% | ៣% |
| ៣៦៤ថ្ងៃ (D364) | ២១ ឧសភា ២០២០ | ២០០ (ពីររយប៊ីលាន) រៀល | ៣,០៥% | ៣% |



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥១៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ការដេញថ្លៃត្រូវធ្វើតាមផ្លែតហ្វមធនាគារជាតិនៃកម្ពុជា (NBCP) ក្នុងករណី NBCP មិនអាចអនុវត្តបាន ពាក្យសុំដេញថ្លៃត្រូវបញ្ជូនតាមសារអេឡិចត្រូនិក bod_lpco@nbc.org.kh ឬដាក់ក្នុងស្រោមសំបុត្របិទជិត និងផ្ញើមកនាយកដ្ឋានប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជា ឱ្យបានមុនម៉ោង ១២:០០ ថ្ងៃត្រង់ នាថ្ងៃដដែល។

លទ្ធផលនៃការដេញថ្លៃនឹងប្រកាសនៅម៉ោង ២:០០ រសៀល នាថ្ងៃដដែល។ គ្រឹះស្ថានដែលទទួលជោគជ័យត្រូវអនុវត្តតាមសេចក្តីណែនាំលើការអនុវត្តប្រតិបត្តិការ LPCO។

គណៈកម្មការដេញថ្លៃរក្សាសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌនៃការដេញថ្លៃប្រតិបត្តិការ LPCO។

សូមទំនាក់ទំនង ៖
លេខទូរស័ព្ទ : (៨៥៥-២៣) ៧២៤ ៥៦៣ ឬ (៨៥៥-២៣) ៧២២ ២២១ EXT. ១០៤៨
សារអេឡិចត្រូនិក : lpco_info@nbc.org.kh